(93)

75/7

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

6/June/2018

សាលាដំបូងខេត្តស្វាយរៀង
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ២៧៧ ចុះថ្ងៃទី០២
ខែ សីហា ឆ្នាំ ២០១៧
សាលក្រមរបៀប
លេខ: ០៨ (ឃ) ចុះថ្ងៃទី
២៧ខែមេសា ឆ្នាំ ២០១៨

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តស្វាយរៀង

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តស្វាយរៀងកាលពីថ្ងៃ ទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៨ និងបន្តនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៨ ដោយមានសមាសភាពដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជំរះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

លោកស្រី [redacted] ជាក្រុមប្រឹក្សាជំនុំជំរះ

លោក [redacted] ជាក្រុមប្រឹក្សាជំនុំជំរះ

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តស្វាយរៀង

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តស្វាយរៀង

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៧៧ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៧ ដែលមានជនជាប់ចោទ:

១-ឈ្មោះ [redacted] សុជាតិ អាយុ ៣៥ឆ្នាំ ភេទ ប្រុស ជាតិ ខ្មែរ របររកស៊ីបើកបររថយន្ត ទីកន្លែងកំណើត[redacted]ខេត្តស្វាយរៀង។ ឪពុកឈ្មោះ[redacted](រ) ម្តាយឈ្មោះ [redacted] (រ)ប្រពន្ធឈ្មោះ [redacted]មានកូន ២ នាក់ ទោសពីមុនគ្មាន (នៅក្នុងឃុំ) មេធាវីការពារឲ្យជនជាប់ចោទលោក [redacted]វន្ថា នឹងលោក [redacted]ភិន ។

២- ឈ្មោះ [redacted] សូនី អាយុ ៣២ឆ្នាំ ភេទ ប្រុស ជាតិ ខ្មែរ របររកស៊ីបើកបររថយន្ត មានទីលំនៅកំណើតនឹងបច្ចុប្បន្ននៅភូមិព្រៃ[redacted]ខេត្តស្វាយរៀង ឪពុកឈ្មោះ [redacted](រ)ម្តាយឈ្មោះ[redacted](រ)ប្រពន្ធឈ្មោះ [redacted] មានកូន ២ នាក់ ទោសពីមុនគ្មាន (នៅក្នុងឃុំ) មេធាវីការពារឲ្យជនជាប់ចោទលោក [redacted]សម្បត្តិ ។

ជាប់ចោទពីបទ: ឃាតកម្មដោយមានទារុណកម្ម នឹងអំពើរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២០៥ នៃក្រម

Scanned with CamScanner

ព្រហ្មទណ្ឌ ។

## ដើមបណ្តឹងរដ្ឋប្បវេណី

១-ឈ្មោះ [redacted] ស្រីឡូត ភេទ ស្រី អាយុ ៣៥ឆ្នាំ ជាតិ ខ្មែរ របរកសិករធ្វើស្រែ មាន ទី លំនៅសព្វថ្ងៃនៅភូមិ [redacted] ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។

២-ឈ្មោះ [redacted] សុវណ្ណ ភេទ ប្រុស អាយុ ៣៨ឆ្នាំ ជាតិ ខ្មែរ របរកសិករធ្វើស្រែ មានទីលំនៅសព្វថ្ងៃនៅភូមិដូនមៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។

-ដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវីការពារគឺលោក អ៊ុក ស៊ីណាកេត

-តុលាការប្រកាសបើកសវនាការ

-តុលាការប្រកាសអំពីសមាសភាពជំនុំជំរះ

-តុលាការសួរអំពីអត្តសញ្ញាណជនជាប់ចោទ

-តុលាការប្រាប់សិទ្ធិដល់ដើមបណ្តឹងរដ្ឋប្បវេណី

-តុលាការប្រាប់សិទ្ធិដល់សាក្សី

-ជនជាប់ចោទមិនជំទាស់ នឹង សមាសភាពជំនុំជំរះថ្ងៃនេះទេ

-តុលាការប្រាប់តំណាងអយ្យការធ្វើការផ្តើមចោទប្រកាន់ឈ្មោះ [redacted] សុជាតិ និងឈ្មោះ [redacted] សូនី ពីបទៈ ឃាតកម្មដោយមានទារុណកម្ម នឹងអំពើរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី ០២-០៨-២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ ។

## ដំណើររឿងហេតុ

កាលពីថ្ងៃទី១២ ខែ មករា ឆ្នាំ ២០១៨ សមត្ថកិច្ចជំនាញនគរបាលព្រហ្មទណ្ឌខេត្តស្វាយរៀង បានទទួលពាក្យបណ្តឹងពីឈ្មោះ [redacted] សុវណ្ណ ប្តឹងឲ្យសមត្ថកិច្ចជួយស្រាវជ្រាវរកកូនស្រីឈ្មោះ [redacted] សុម៉ាលីន ដែលបានបាត់ខ្លួនកាលពីថ្ងៃទី ០៣-០៨-២០១៧ នៅពេលដែលកូនស្រីខ្លួនត្រឡប់មកពីផ្ទះនៅខេត្តព្រះវិហារ មកធ្វើការនៅខេត្តស្វាយរៀងវិញ នៅពេលមកដល់ចំណុចផ្សារជីភូក៏បាត់ដំណឹង ។ ក្រោយទទួលបានពាក្យបណ្តឹងសមត្ថកិច្ចបានធ្វើការស្រាវជ្រាវកំណត់មុខសញ្ញានឹងឈានទៅដល់ការឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted] សុជាតិ ដើម្បីធ្វើការសាកសួរ នៅចំពោះមុខសមត្ថកិច្ចឈ្មោះ [redacted] សុជាតិ បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តអំពើរំលោភសម្លាប់នារីរងគ្រោះនៅចំណុចភូមិតាពៅ សង្កាត់បាវិត ក្រុងបាវិត ខេត្តស្វាយរៀង កាលពីថ្ងៃទី ០២-០៨-២០១៧ នោះពិតមែន ដោយធ្វើសកម្មភាពជាមួយបក្ខពួកម្នាក់ទៀតឈ្មោះ [redacted] សូនី ជាអ្នករត់តាក់ស៊ីដូចគ្នា ។ ក្នុងពេលនោះសមត្ថកិច្ចក៏បានធ្វើការឆែកឆេរក្នុងរថយន្តម៉ាកហាយលែនឌ័រពណ៌សជារបស់ឈ្មោះ [redacted] សុជាតិ រកឃើញខ្សែកកាឡែចំនួន ១ខ្សែ នឹងជញ្ជៀនដាំត្បូងពណ៌សកាឡែ១វង់ របស់ជនរងគ្រោះនៅក្នុងរថយន្តទៀតផង ។ នៅក្នុងថ្ងៃដដែលនោះដោយមានកិច្ចសហការជាមួយកំលាំងជំនាញនគរ បា

Scanned with CamScanner

លព្រហ្មទណ្ឌក់រិតធ្ងន់នៃនាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ក៏បានឃាត់ខ្លួនជនសង្ស័យដែលជាបក្ខពួកម្នាក់ទៀតឈ្មោះ[redacted] សូនី នាំមកសាកសួរនឹងកសាងសំណុំរឿងបញ្ជូនមកអយ្យការចាត់ការតាមច្បាប់ ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ[redacted]សុជាតិ បានឆ្លើយបញ្ជាក់ក្នុងពេលសវនាការថាៈ កាលពីថ្ងៃទី ០២-០៨-២០១៧ វេលាម៉ោងជាង ២រសៀល ខ្លួនដឹកម៉ូយប្រុសៗចំនួន ៥នាក់នឹងស្រីម្នាក់ចេញពីភ្នំពេញឆ្ពោះទៅបាវិត ។ ពេលមកដល់អ្នកលឿងក្បាលស្ពានខាងលិចខ្លួនបានដាក់ម៉ូយប្រុសៗចំនួន ២នាក់ចុះ នឹងបានជួបឈ្មោះ មុន្នី(ឈ្មោះពិត[redacted] សូនី)ដឹកម៉ូយមកដល់ក្រោយខ្លួនដែរដោយបើកឡានយឺតៗ ខ្លួនបានប្រាប់ឈ្មោះ មុន្នី(ឈ្មោះពិត [redacted] សូនី)ថាៈ មានស្រីស្អាត ឯឈ្មោះ មុន្នី(ឈ្មោះ[redacted] ផ្លេក សូនី)យកទៅ រួចក៏បង្ហួសឡានទៅមុនខ្លួន ។ នៅពេលខ្លួនមកដល់ផ្សារកេអណ្ដើកខ្លួនបានដាក់ម៉ូយប្រុសៗ២នាក់ទៀតចុះ ខ្លួនក៏បើកឡានមកដល់ស្វាយរៀងឈ្មោះ មុន្នី(ឈ្មោះ[redacted] [redacted] សូនី)ទូរសព្ទ័មកប្រាប់ខ្លួនថាវានៅចាំមុខពេទ្យជីភូ តែលេខទូរសព្ទ័ដែលឈ្មោះ មុន្នី(ឈ្មោះពិត ផ្លេក សូនី)គេមករកខ្លួនក្នុងពេលនោះពុំមែនលេខវាទេ(ខ្លួនមិនចាំលេខដែលគេមករកខ្លួននោះទេ)នៅពេលខ្លួនបើកឡានទៅដល់មុខពេទ្យជីភូ ខ្លួនដាក់ម៉ូយប្រុសម្នាក់ទៀតចុះ នៅសល់តែនារីម្នាក់ដែលទៅបាវិត ។ នៅពេលនោះឈ្មោះ មុន្នី(ឈ្មោះពិត [redacted] សូនី)បានឡើងជិះឡានខ្លួនបាំងខាងក្រោយជាមួយនារីដែលជាជនរងគ្រោះ ហើយឈ្មោះ មុន្នី(ឈ្មោះពិត[redacted] សូនី)ប្រាប់ខ្លួនថាៈ បើកទៅយកពួកម៉ាកវានៅកែងមេសថ្ងក(សាលាស្រុកចន្ទ្រា) ពេលខ្លួនបើកឡានទៅដល់ឈ្មោះ មុន្នី ប្រាប់ថា ពួកម៉ាកវាចាំយូរទៅបាត់ហើយ ខ្លួនក៏បើកឡានមកបាវិតវិញតាមសង្កាត់បាទី ពេលខ្លួនបើកឡានទៅដល់ថ្នល់កែង(ផ្លូវមួយទៅសង្កាត់ប្រាសាទ នឹងមួយទៅសង្កាត់បាទី)ហួសថ្នល់កែង ១០០មឈ្មោះ មុន្នី(ឈ្មោះពិត [redacted] សូនី)ចាប់ផ្ដើមធ្វើសកម្មភាពចាប់ដៃជនរងគ្រោះចងទៅក្រោយ រួចរំលោភជនរងគ្រោះនៅក្នុងឡានខ្លួន នៅពេលខ្លួនបើកឡានចូលទៅដល់ផ្លូវចូលរោងចក្រយឺងមេខ័រ ឈប់ឡានអែបខាងកើតបែមុខទៅជើងឈ្មោះ មុន្នី ចុះពីឡានខ្លួនឡើងទៅរំលោភម្ដងតែខ្លួនឃើញជនរងគ្រោះដេកសន្លប់ប្រដាប់ភេទខ្លួនទន់ខ្លួនមិនបានរំលោភទេ ខ្លួនស្រាយកន្សែងចេញពីដៃជនរងគ្រោះ នឹងប្រាប់ឈ្មោះ មុន្នី(ឈ្មោះពិត[redacted] សូនី)ថា កុំសម្លាប់គេ នៅពេលនោះឈ្មោះ មុន្នី(ឈ្មោះពិត [redacted] សូនី)បានឆក់យកកន្សែងពីដៃខ្លួនទៅទាកកជនរងគ្រោះនឹងថាកុំទុករួចក៏ទាញជនរងគ្រោះទំលាក់ចេញពីក្នុងឡានអូសយកទៅចោលក្នុងស្រែមានទឹកតិចៗប្រហែល ៦ម៉ែត្រពីឡានដោយមានដុំថ្មដាក់សង្កត់ពីលើផង។ នៅពេលអូសសពជនរងគ្រោះទៅចោលរួចហើយខ្លួនបើកឡានចេញមកតាមផ្លូវរោងចក្រយឺងមេខ័រ បានប្រហែល ២០០ម៉ែត្រឈ្មោះ មុន្នី(ឈ្មោះពិត[redacted] សូនី)ក៏ជំលាក់ឥវ៉ាន់ជនរងគ្រោះចោលតាមទ្វាឡានខាងក្រោយ នឹងជិះឡានជាមួយគ្នាមកដល់ជីភូបែកគ្នារៀងៗខ្លួនតែម្ដង ។ លុះដល់ថ្ងៃទី ០៨-

Scanned with CamScanner

០៨-២០១៧ ខ្លួនទៅដឹកម៉ូយនៅបាវិតឃើញឈ្មោះ មុន្នី(ឈ្មោះពិត[redacted]សុនី)បានម៉ូយទៅភ្នំពេញមុនខ្លួន ជាមួយគ្នានោះខ្លួនក៏ត្រូវបានសមត្ថកិច្ចស្ទាក់ឡានឃាត់នៅត្រង់របសឹងនាំមកសាកសួរនៅសមត្ថកិច្ចនគរបាលខេត្តស្វាយរៀង និងបានបញ្ជូនខ្លួនជាបន្តបន្ទាប់មកតុលាការឃុំខ្លួនរហូតដល់សព្វថ្ងៃ ។ ចំពោះខ្សែកនឹងជញ្ចៀនជនរងគ្រោះពេលព្រឹកខ្លួនបោសឡានឃើញនៅក្នុងឡានខ្លួនៗយកទុកក្នុងប្រអប់ឡានខាងមុខនឹងត្រូវសមត្ថកិច្ចឆែកឆេររកឃើញដកហូតពីខ្លួនតែម្តង ។

-ជនជាប់ចោទឈ្មោះ [redacted] សុនី បានឆ្លើយបដិសេធក្នុងពេលសវនាការថា: កាលពីថ្ងៃទី ០២-០៨-២០១៨ វេលាម៉ោង ៨ព្រឹក ខ្លួនទទួលទូរសព្ទ័របស់អ្នកទាក់ទងម៉ូយនៅបាវិត នឹងថាឲ្យខ្លួនទៅយកម៉ូយចំនួន ២នាក់ជាជនជាតិចិនពីកាស៊ីណូម៉ាការទៅព្រលានយន្តហោះភ្នំពេញ នៅពេលទៅដល់ព្រលានយន្តហោះម៉ោង ១១ថ្ងៃត្រង់ ខ្លួនបានដាក់ភ្ញៀវចុះទាំងពីរនាក់ នឹងចូលទៅស៊ីបាយនៅមុខព្រលានយន្តហោះ។ ជាមួយគ្នាខ្លួនបើកឡានមកចាប់ម៉ូយនៅបេនអូឡាំពិចនៅវេលាម៉ោងប្រហែល ១រសៀល ពេលខ្លួនចេញឡានមកដល់ផ្សារប្រសូតិជាមួយម៉ូយចំនួន ៣នាក់ ដែលម៉ូយទាំងអស់នេះចុះនៅផ្សារប្រសូតិទាំងអស់ក្នុងអំឡុងម៉ោង ៤រសៀល ។ បន្ទាប់ពីម៉ូយចុះពីឡានខ្លួនអស់ខ្លួនទទួលដឹកគុអ៊ីណុកចំនួន១ និងកៅអីជ័រចំនួន ១០ របស់ឈ្មោះ តុលា នៅផ្សារប្រសូតិ យកទៅឲ្យពូឈ្មោះ វ៉ាន់ នៅភូមិព្រៃតាញ៉យ ខ្លួនមកដល់ភូមិព្រៃតាញ៉ញនៅម៉ោងប្រហែល ៥និង ៣០នាទីល្ងាច ដាក់គុ នឹងកៅអីជ័រនៅផ្ទះពូវ៉ាន់ ខ្លួនក៏បើកឡានចូលផ្ទះលាងឡាន ដោយពុំបានចេញទៅណាទៀតនោះទេ ។ ខ្លួនសុំបដិសេធលើសំដីរបស់ឈ្មោះ [redacted] សុជាតិ ដែលបានឆ្លើយដាក់ខ្លួនថា: ខ្លួនបានទៅចូលរួមរំលោភសម្លាប់ជនរងគ្រោះ កាលពីថ្ងៃទី ០២-០៨-២០១៧ ថារឿងនេះពុំពិតទេ ។ ជាមួយគ្នានេះខ្លួនក៏ពុំដែលមានទំនាក់ប្រព័ន្ធទូរស័ព្ទជាមួយឈ្មោះ [redacted] សុជាតិ ម្តងណាទេ ។

តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ស្រីឡូត បានឆ្លើយបញ្ជាក់ថា : កាលពីថ្ងៃទី ២៨-០៧-២០១៧ វេលាម៉ោង៩ព្រឹកខ្លួនបានទូរស័ព្ទទៅកូនឈ្មោះ [redacted] សុម៉ាលីន ធ្វើការនៅកាស៊ីណូនៅក្រុងបាវិត ដើម្បីឲ្យឡើងមកផ្ទះនៅខេត្តព្រះវិហា ចូលរួមខួបកំណើតឲ្យប្អូនកូនខ្លួនក៏ឡើងមកខេត្តព្រះវិហា នឹងបានសំរាកនៅទីនោះបាន៥ថ្ងៃ នឹងនៅថ្ងៃទី ០២-០៨-២០១៧ កូនខ្លួនក៏បានត្រឡប់ទៅធ្វើការនៅក្រុងបាវិតវិញ នៅម៉ោង ១២ថ្ងៃត្រង់ខ្លួនតេសួរកូនស្រីថាទៅដល់ណាហើយ កូនខ្លួនប្រាប់ថា មកដល់ភ្នំពេញហើយកំពុងជិះម៉ូតូកង់បីទៅរកឡាននៅច្បារអំពៅ មួយម៉ោងក្រោយមកខ្លួនបានតេសួរកូនថាទៅដល់ណាហើយ កូនស្រីខ្លួនប្រាប់ថា មកដល់កៀនស្វាយហើយ នឹងរហូតដល់ម៉ោង ៥ល្ងាចខ្លួនបានតេទៅកូនស្រីម្តងទៀត កូនស្រីខ្លួនប្រាប់ថា មកដល់ស្វាយរៀងហើយ ដល់ត្រង់ចំណុចផ្សារជីភ្វ ហើយឡានគាត់ស៊ីកំពុងទៅយកម៉ូយម្នាក់ទៀតចូលទៅតាមផ្លូវលំ កូនខ្លួនប្រាប់ថា វាមិនស្គាល់ផ្លូវនឹងទេ។លុះដល់ម៉ោង ៦ល្ងាចខ្លួនតេទៅកូនស្រីខ្លួនម្តងទៀតចូលតែគ្មានអ្នកលើក នឹងបន្តតេមក

Scanned with CamScanner

កូនហេតុតែទូរស័ព្ទទាក់ទងគ្នាលេងបាន ដោយបារម្មណ៍ពីកូនខ្លួនក៏ឡើងមកស្វាយរៀង តាមសួររកកូនតែរកមិនឃើញ ហេតុដល់ថ្ងៃទី ០៥-០៨-២០១៧ ខ្លួនក៏បានដាក់ពាក្យប្តឹងទៅសមត្ថកិច្ចឲ្យជួយស្រាវជ្រាវ ទើបឃើញសាកសពសមត្ថកិច្ចក៏ប្រគល់សាកសពឲ្យខ្លួនយកទៅធ្វើបុណ្យតាមប្រពៃណីតែម្តង ។

តាមចម្លើយសាក្សីបំភ្លឺឈ្មោះ[redacted]សុថា បានឆ្លើយបញ្ជាក់ថា: កាលពីថ្ងៃទី ០២-០៨-២០១៧ ខ្លួនដឹងតាមបណ្តាញសង្គមថា មានបាត់នារីជំទង់ម្នាក់ចេញដំណើរពីខេត្តព្រះវិហារមកស្វាយរៀង នឹងធ្វើការនៅបាវិត ខ្លួនបានទាក់ទងទៅអធិការនគរបាលក្រុងបាវិតឲ្យគាត់ជួយទាក់ទងរក ។ ដល់ថ្ងៃទី ០៥-០៨-២០១៧ វេលាប្រហែលម៉ោង ១រសៀលជាង ខ្លួនដឹងពត៍មានថា ឃើញសាកសពក្មេងស្រីនៅក្នុងស្រែ នៅភូមិកា៣ សង្កាត់បាវិត ខ្លួនបាននាំក្រុមគ្រួសារអ្នកប្តឹងឲ្យទៅមើលសាកសព នឹងបានចង្អុលបង្ហាញថាជាកូនស្រីរបស់ខ្លួន ។ ជុំវិញការឃើញសាកសពខ្លួនទទួលបានពត៌មានថា មានអ្នកឃើញរថយន្តពត៌សខ្ចស់ចតក្បែរកន្លែងសាកសពកាលពីល្ងាចថ្ងៃទី ០២-០៨-២០១៧ ។ នៅថ្ងៃទី ០៦-០៨-២០១៧ សមត្ថកិច្ចយើងបានធ្វើការស្រាវជ្រាវដឹងអ្នកឃើញរថយន្តចតនៅល្ងាចថ្ងៃទី ០២-០៨-២០១៧ នៅក្បែរសាកសពគឺឈ្មោះ[redacted] សាវី និងប្តីឈ្មោះ[redacted] សាមុត ។ នៅពេលដឹងហើយខ្លួនធ្វើការថតរថយន្តចំនួន ៣ប្រភេទគឺ រថយន្តលុចស៊ីស, រថយន្តហាយលេនឌឺ និងរថយន្តសាំងយ៉ុង ទៅបង្ហាញឲ្យសាក្សីមើល សាក្សីទាំងពីរនាក់ប្តីប្រពន្ធបញ្ជាក់ថា ឡានហាយលេនឌឺ ខ្លួនក៏បានពិនិត្យផ្លូវមានតែតាមរោងចក្រយីងមេខ័រ ក៏ឆែកកម្មរ៉ាសុវត្ថិភាពរោងចក្រយីងមេខ័រឃើញមានឡានហាយលេនឌឺពត៌សបើកគាត់នៅវេលាម៉ោង ៦ និង ៥៥នាទីល្ងាច ថ្ងៃទី ០២-០៨-២០១៧ ខ្លួនបានយកលេខទូរស័ព្ទអ្នករត់គាត់ស៊ីឡានហាយលេនឌឺចំនួន ១១នាក់ ឆែកឃើញសេវ៉ាហៅចូលលេខទូរស័ព្ទឈ្មោះ[redacted] សុជាតិ នៅវេលាម៉ោង ៦ជាង នៅចំណុចកើតហេតុក្នុងសង្កាត់បាទី។ លុះដល់ថ្ងៃទី ០៨-០៨-២០១៧ សមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ[redacted] សុជាតិ នឹងរថយន្តរបស់ខ្លួនមកសាក់សួរនៅការិយាល័យព្រហ្មទណ្ឌ បន្តឆែកឆេរក្នុងរថយន្តរបស់ឈ្មោះ [redacted] សុជាតិ បានឃើញចិញ្ចៀន និងខ្សែកនៅក្នុងឡាន តែឈ្មោះ[redacted]សុជាតិ ប្រកែកខ្លួនបានឲ្យម្តាយមីងឈ្មោះ [redacted] ចន្ធូ មកចង្អុលបង្ហាញស្គាល់ថាពិតជាខ្សែកនិងជញ្ជៀនក្មួយស្រីខ្លួន(សព) ច្រកប្រើរាល់ថ្ងៃ ទើបឈ្មោះ[redacted]សុជាតិ ឆ្លើយសារភាពថា ខ្លួននឹងឈ្មោះ [redacted] សូនី ជាអ្នកបានប្រព្រឹត្តក្នុងរឿងនេះ ទើបសមត្ថកិច្ចខ្លួនឈានទៅចាប់ឃាត់ខ្លួនឈ្មោះ[redacted]សូនី បញ្ជូនមកគុលាការឃុំខ្លួនរហូតដល់សព្វថ្ងៃ ។

មេធាវីការពារឲ្យដើមបណ្តឹងបានធ្វើសេចក្តីសន្និដ្ឋានថា លោកស្រីមិនយល់ទាស់ទៅលើនីតិវិធីរបស់តុលាការក្នុងពេលនេះទេ ដោយលោកស្រីស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជំរះបន្តនីតិវិធីទៅតាមច្បាប់ ។ ម៉្យាងកូនក្តីលោកស្រីនៅឆ្ងាយពិបាកក្នុងការចុះឡើង ហើយជនជាប់ចោទ នឹងសាក្សីទាំងអស់ក៏មានវត្តមានគ្រប់អស់ហើយ ដែលគប្បីក្រុមប្រឹក្សាជំនុំជំរះបន្ត

Scanned with CamScanner

នីតិវិធី ។

តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា: លោកមិនជំទាស់ទៅលើនីតិវិធីខាងលើរបស់ក្រុមប្រឹក្សាជំនុំជំរះទេ ដោយលោកស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជំរះបន្តនីតិវិធីជំនុំជំរះទៅតាមច្បាប់ ។

មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ[redacted]សូនី លោក[redacted]សម្បត្តិ បានធ្វើសេចក្ដីសន្និដ្ឋានការពារកូនក្ដីលោកក្នុងពេលសវនាការថា: លោកមិនជំទាស់ទៅលើនីតិវិធីរបស់តុលាការក្នុងពេលនេះទេ តែលោកស្នើសុំឲ្យតំណាងអយ្យការពិនិត្យទៅលើការសួរដេញដោលសាក្សីដែលដោះបន្ទុកឲ្យកូនក្ដីខ្លួន[redacted] សូនី)ការសួរសំណួររបស់តំណាងអយ្យការទៅលើសាក្សីរបស់កូនក្ដីខ្លួនហាក់មានគុំនៀបតាមផ្លូវចិត្ត នឹងសំណួរមានការបំភិតបំភ័យដែលធ្វើឲ្យសាក្សីមិនហានឆ្លើយតាមការពិត ខ្លួនជាមេធាវីមិនតាំងសំណួរសួរទៅលើសាក្សីទាំងអស់នេះទេក្នុងពេលនេះ ។ ម៉្យាងទៀតតាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុជាតិ ថា នៅមុនពេលដែល[redacted] សុជាតិ នឹងឈ្មោះ [redacted] សូនី)មកដល់អ្នកលឿងបានជួបគ្នានៅអ្នកលឿងត្រើយខាងលិច ពួកគេបានឈប់ឡានសួរគ្នាថា បានម៉ូយប៉ុន្មាននាក់ ឯឈ្មោះ [redacted] សុជាតិបានប្រាប់ឈ្មោះ[redacted]សូនី ថាមានស្រីស្អាតវើយ ហើយពួកគេទាំងពីរនាក់ក៏មានទំនាក់ទំនងគ្នាតាមរយៈប្រពន្ធទូរសព្ទ័ចាប់ពីចេញពីអ្នកលឿង មកដល់ផ្សារកអណ្ដើក នឹងរហូតមកដល់ខេត្តស្វាយរៀង លោកស្នើសុំឲ្យតុលាការចាត់របៀបការជំនុំជំរះក្នុងពេលនេះនឹងស្នើសុំឲ្យតុលាការចាត់ឲ្យមន្ត្រីជំនាញធ្វើការស្រាវជ្រាវលើប្រពន្ធទូរសព្ទ័រវាងកូនក្ដីខ្លួន([redacted] សូនី) នឹងប្រពន្ធទូរសព្ទ័ឈ្មោះ[redacted]សុជាតិ ថាតើពួកគេមានបានទំនាក់ទំនងគ្នាតាមប្រពន្ធទូរសព្ទ័ទេ ?

**សាលាដំបូងខេត្តស្វាយរៀង**

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី
-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
-ក្រោយពីបានស្ដាប់ចម្លើយសាក្សី
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្ដឹងរដ្ឋប្បវេណី
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ
-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
-ក្រោយពីបានពិនិត្យ នឹងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

-សំណុំរឿងព្រហ្មទណ្ឌលេខ ២៧៧ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តស្វាយរៀង ពុំទាន់បានអង្កេតបានពេញលេញនៅឡើង ដែលគប្បីក្រុមប្រឹក្សាជំនុំជំរះសម្រេចចាត់របៀប ។

-លោក [redacted]សម្បត្តិ មេធាវីការពារជនជាប់ចោទឈ្មោ[redacted]សូនី ស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជំរះសម្រេចចាត់របៀបលើសំណុំរឿងនេះ នឹងសុំឲ្យមន្ត្រីជំនាញស្រាវជ្រាវលើប្រព័ន្ធទូរសព្ទ័នៃការទំនាក់ទំនងគ្នារវាងកូនក្ដីលោក ([redacted]សូនី នឹងឈ្មោះ [redacted] សុជាតិ) ថាតើពួកគេទាំងពីរនាក់មានទំនាក់ទំនងគ្នាមុនពេលកើតហេតុតាមប្រព័ន្ធទូរសព្ទ័ដែរទេ?

Scanned with CamScanner

## ហេតុដូច្នេះ សម្រេច

១-ចាត់របៀបលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៧៧ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៧ ចាប់ពីពេលនេះតទៅ ។

២-បង្គាប់ឲ្យមន្ត្រីនគរបាលយុត្តិធម៌នៃស្នងការនគរបាលខេត្តស្វាយរៀង ធ្វើការស្រាវជ្រាវស្វែងរកភស្តុតាងដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សូនី ទៅលើប្រព័ន្ធទូរស័ព្ទ [redacted] សុជាតិ ដែលមានលេខ( [redacted] ) នឹងប្រព័ន្ធទូរស័ព្ទឈ្មោះ [redacted] សូនី [redacted] នឹងលេខ [redacted] )ថាតើមុនពេលកើត ហេតុថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១៧ ចាប់ពីម៉ោង ៣រសៀល រហូតដល់ម៉ោង ៨យប់ ប្រព័ន្ធទូរស័ព្ទមានទំនាក់ទំនងជាមួយគ្នាដែរឬទេ? ឬក៏មានប្រព័ន្ធទូរស័ព្ទផ្សេងគេចូលមកទំនាក់ទំនងជាមួយប្រព័ន្ធទូរស័ព្ទរបស់ឈ្មោះ [redacted] សុជាតិ ។

៣-សាលក្រមនេះជុំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ ឆឹយ សុជាតិ ,ឈ្មោះ ផ្លេក សូនី និងដើមបណ្តឹងរដ្ឋប្បវេណី ។

| ក្រឡាបញ្ជី | ក្រុមប្រឹក្សាជំនុំជំរះ | ប្រធានក្រុមប្រឹក្សាជុំនុំជំរះ |
|---|---|---|
| ហត្ថលេខានឹងឈ្មោះ | ហត្ថលេខានឹងឈ្មោះ | ហត្ថលេខានឹងឈ្មោះ |
| [redacted] | [redacted], [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ២កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅស្វាយរៀង ថ្ងៃទី ០៧.. ខែ មិថុនា ឆ្នាំ ២០១៨

ក្រឡាបញ្ជី

[redacted]

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

Scanned with CamScanner